# កន្លែងថ្វាយបង្គំ

## (ការថ្វាយបង្គំដែលផ្គាប់ព្រះទ័យទ្រង់)

ការប្រកាសព្រះគ្រីស្ទពីគម្ពីរសញ្ញាចាស់ ចោទិយកថា ១២

អ្នកនិពន្ធ៖ រុហ្វ លេភិឡារ

## កាលៈទេសៈប្រវត្តិសាស្ត្រ

ជនជាតិអ៊ីស្រាអែលបានបញ្ចប់ការធ្វើដំណើររបស់ពួកគេចេញពីអេស៊ីព្ទ ហើយការវង្វេងនៅក្នុងទីរហោស្ថាន រយៈពេល៤០ឆ្នាំក៏បានបញ្ចប់ដែរ។ ពួកគេស្ថិតនៅភាគខាងកើតយ័រដាន់ កំពុងត្រៀមខ្លួនជាស្រេចដើម្បីចូលទៅក្នុងទឹកដីសន្យា។ កណ្ឌចោទិយកថាកត់ត្រាអំពីសេចក្តីអធិប្បាយបីរបស់ម៉ូសេទៅកាន់បណ្តាជនអ៊ីស្រាអែល ដើម្បីលើកទឹកចិត្តពួកគេអោយកាន់តាមក្រិត្យវិន័យ។

**សារនៃអត្ថបទ**

អ៊ីស្រាអែលនឹងជួបប្រទះសាសនារបស់ប្រជាជនរស់នៅទីនោះ នៅលើទឹកដីកាណានដែលពួកគេនឹងចូលទៅ។ ពួកគេនឹងឃើញព្រះក្លែងក្លាយដែលអ្នកស្រុកកាណានថ្វាយបង្គំ ហើយនឹងឃើញពីរបៀបពួកគេថ្វាយបង្គំព្រះក្លែងក្លាយទាំងនោះ។ សំណួរធំមួយសំរាប់ប្រជាជនអ៊ីស្រាអែលគឺ «តើយើងត្រូវថ្វាយបង្គំព្រះជាម្ចាស់យ៉ាងដូចម្តេច?» តើយើងអាចយកវិធីខ្លះពីពួកគេមកប្រើបានដែរទេ? តើយើងអាចថ្វាយបង្គំព្រះជាម្ចាស់តាមមធ្យោបាយ ដែលអ្នកស្រុកកាណានថ្វាយបង្គំព្រះរបស់ពួកគេមកប្រើបានដែរទេ? យោងតាមអត្ថបទនេះ ចម្លើយពិតជាឆ្លើយថា ទេ។ ពេលខ្លះមនុស្សចាប់មិនបានអត្ថន័យចេញពីអត្ថបទនេះសំរាប់អ៊ីស្រាអែលទេ ហើយគេគ្រាន់តែឆ្លើយថា អ៊ីស្រាអែលមិនត្រូវថ្វាយបង្គំព្រះក្លែងក្លាយរបស់ស្រុកកាណានឡើយ ប៉ុន្តែអត្ថបទនេះនិយាយច្រើនជាងនេះទៅទៀតគឺ អ៊ីស្រាអែលមិនអាចថ្វាយបង្គំព្រះយេហូវ៉ាដ៏ពិតតាមមធ្យោបាយ ដែលអ្នកស្រុកកាណានថ្វាយបង្គំព្រះក្លែងក្លាយទាំងនោះទេ។ អត្ថបទនេះបានប្រាប់រួចហើយថា ព្រះជាម្ចាស់នឹងជ្រើសរើសទីកន្លែងមួយ ដើម្បីឲ្យអ៊ីស្រាអែលថ្វាយបង្គំទ្រង់ (ក្រោយមកទ្រង់ជ្រើសរើសយកយេរូសាឡិម) ហើយពួកគេត្រូវតែទៅទីកន្លែង ដែលទ្រង់បានជ្រើសរើសនោះ។

*តើអត្ថបទនេះបង្រៀនអ្វីពីព្រះ?*

- មានការថ្វាយបង្គំតែមួយគត់ ដែលគាប់ព្រះហឫទ័យព្រះជាម្ចាស់គឺ ថ្វាយបង្គំផ្គាប់ព្រះទ័យទ្រង់ ដែលស្របតាមព្រះបន្ទូលទ្រង់។
- ព្រះជាម្ចាស់គ្រប់គ្រងប្រវត្តិសាស្ត្រមនុស្សលោក ពីព្រោះពេលក្រោយមកទៀត យើងឃើញថា ទ្រង់បានជ្រើសរើសទីកន្លែងមួយ ហើយផ្គត់ផ្គង់អ៊ីស្រាអែល ដើម្បីអោយពួកគេអាចសង់ព្រះវិហារបាន។

**ទំនាក់ទំនងភ្ជាប់ទៅនឹងអត្ថបទក្រោយមកទៀតក្នុងគម្ពីរសញ្ញាចាស់**

ជំពូកនេះមានសារៈសំខាន់ខ្លាំងណាស់ក្នុងការជួយយើងឲ្យយល់កណ្ឌគម្ពីរនៅក្នុងសញ្ញាចាស់ ដែលចែងទុកបន្ទាប់ពីអត្ថបទនេះ។ ទីបំផុតក្រុងយេរូសាឡិមក្លាយជាទីកន្លែង ដែលព្រះជាម្ចាស់តាំងព្រះនាមទ្រង់ឡើង (១ពង្សាវតារក្សត្រ ៨:១៦; ១១:៣៦; ២ពង្សាវតារក្សត្រ ២១:៤,៧; ២របាក្សត្រ ៣៣:៤,៧) សេចក្តីសន្យារបស់ព្រះជាម្ចាស់នៅក្នុង ចោទិយកថា ជំពូក២៨ អំពីទីកន្លែងដែលទ្រង់នឹងជ្រើសរើសបានសំរេចដោយសារការ

ជ្រើសរើសនេះ ដូច្នេះជំពូកនេះប្រាប់ពួកអ៊ីស្រាអែលដែលរស់ក្រោយរជ្ជកាលស្តេចដាវីឌថា ព្រះជាម្ចាស់ជ្រើសរើសក្រុងយេរូសាឡិម ដូច្នេះអ៊ីស្រាអែលទាំងអស់ត្រូវទៅក្រុងយេរូសាឡិម ដើម្បីថ្វាយបង្គំព្រះជាម្ចាស់។ នៅពេលអ៊ីស្រាអែលបែងចែកជាពីរ អាណាចក្រខាងជើងហៅថា អ៊ីស្រាអែល (មានក្រុងសាម៉ារីជារាជធានី) បានតាំងកន្លែងថ្វាយបង្គំឡើងខុសពីការបង្គាប់របស់ព្រះក្នុងជំពូកនេះ (ពីព្រោះគេមិនចង់ទៅយេរូសាឡិមដែលនៅអាណាចក្រខាងត្បូង [យូដា])។ អត្ថបទនេះប្រាប់យើងថា ជនជាតិយូដាតែងតែនិយាយថា ក្រុងយេរូសាឡិមគឺជាកន្លែងតែមួយគត់សំរាប់គ្រប់គ្នាមកថ្វាយបង្គំព្រះជាម្ចាស់។

**ទំនាក់ទំនងភ្ជាប់ទៅនឹងគម្ពីរសញ្ញាថ្មី**

ផ្នែកខាងលើមាន សារៈសំខាន់ណាស់ក្នុងការយល់ពីការសន្ទនារវាងព្រះយេស៊ូវ និងស្ត្រីសាសន៍សាម៉ារីក្នុងយ៉ូហាន ជំពូក៤។ សំណួររបស់ស្ត្រីបានផ្អែកលើការជជែកគ្នាអំពីទីកន្លែងមួយណា ដែលពួកគេអាចថ្វាយបង្គំព្រះបាន។ ដោយផ្អែកចោទិយកថា ១២ ជនជាតិយូដានិយាយថា ត្រូវតែនៅក្រុងយេរូសាឡិម (យ៉ូហាន ៤:២០) ប៉ុន្តែសាសន៍សាម៉ារី (សូមចងចាំថា អាណាចក្រខាងជើងមានសាម៉ារីជារាជធានី) បានបង្កើតកន្លែងផ្សេងទៀត ដើម្បីថ្វាយបង្គំព្រះជាម្ចាស់។ យើងត្រូវយល់អំពីការជជែកនេះ ដើម្បីអោយយើងឃើញសារៈសំខាន់នៃចម្លើយរបស់ព្រះយេស៊ូវនៅក្នុង យ៉ូហាន ៤:២០-២១។ នៅសតវត្សទីមួយ ចម្លើយរបស់ព្រះយេស៊ូវធ្វើឲ្យមនុស្សជាច្រើនភាំងស្មារតី។ ទីកន្លែងមានសារៈសំខាន់ណាស់ចំពោះពួកគេ។ នៅក្នុងចោទិយកថា ជំពូក១២ ព្រះជាម្ចាស់មានបន្ទូលថា ទីកន្លែងសំខាន់ណាស់ គឺពួកគេត្រូវថ្វាយបង្គំនៅកន្លែងដែលទ្រង់ជ្រើសរើសតែប៉ុណ្ណោះ។ ចម្លើយរបស់ព្រះយេស៊ូវបញ្ជាក់ថា ឥឡូវនេះកន្លែងមិនសំខាន់ទេ។ យើងស្ថិតនៅសម័យថ្មី គឺការបង្គាប់របស់ព្រះខ្លះនៅក្នុងចោទិយកថា១២ មិនអាចយកមកអនុវត្តន៍បានឡើយ។ ការថ្វាយបង្គំដោយវិញ្ញាណនិងសេចក្តីពិតនៅក្នុងដំណឹងល្អយ៉ូហាន មានទំនាក់ទំនងយ៉ាងជិតស្និតចំពោះការទុកចិត្ត និងការដើរតាមព្រះយេស៊ូវ។

**សារអធិប្បាយ**

យើងស្ថិតនៅសម័យថ្មី ដូច្នេះការបង្គាប់របស់ព្រះខ្លះនៅក្នុងចោទិយកថា ១២ មិនអាចយកមកអនុវត្តន៍បានឡើយ។ បើសិនដូច្នោះ តើយើងអធិប្បាយព្រះបន្ទូលចេញពី ចោទិយកថា ១២ ទៅកាន់គ្រីស្ទបរិស័ទសព្វថ្ងៃនោះយ៉ាងដូចម្តេច? សំណួរសំខាន់គឺថា រវាងសម័យសម្ព័ន្ធមេត្រីចាស់និងថ្មី តើមានអ្វី*ដូច*គ្នា? តើសម្ព័ន្ធមេត្រីចាសនិងសម្ព័ន្ធមេត្រីថ្មី មានអ្វី*ខុស*គ្នា? គោលការណ៍*ដូច*គ្នាគឺ យើងមិនមានសេរីភាពថ្វាយបង្គំព្រះជាម្ចាស់តាមរបៀប ដែលយើងប្រាថ្នាចង់បានទេ ប៉ុន្តែយើងត្រូវតែថ្វាយបង្គំព្រះជាម្ចាស់តាមព្រះហឫទ័យទ្រង់ ដែលទ្រង់សំដែងតាមរយៈព្រះបន្ទូល។ ដើម្បីស្រាវជ្រាវព័ត៌មានថែមទៀតអំពីរឿងនេះ យើងណែនាំអ្នកឲ្យអានមេរៀនអំពីការថ្វាយបង្គំ)។ អ្វីដែល*ខុស*គ្នាគឺ ការថ្វាយបង្គំដែលពិតជាផ្គាប់ព្រះហឫទ័យទ្រង់។ យោងទៅតាមចោទិយកថា ១២ ទីកន្លែងមានសារៈសំខាន់ ឯសំរាប់សម្ព័ន្ធមេត្រីថ្មី កន្លែងមិនសំខាន់ទេ តែអ្វីដែលសំខាន់នៅក្នុងសម្ព័ន្ធមេត្រីថ្មីនោះគឺ ព្រះបន្ទូលទ្រង់នៅ យ៉ូហាន ៤:២១-២៤។ ដូច្នេះ ដោយយើងពិចារណាពីចោទិយកថា ១២ សំរាប់អ៊ីស្រាអែល ហើយការពង្រីកតាមព្រះគម្ពីរសំរាប់គ្រីស្ទបរិស័ទ យើងសន្និដ្ឋានសារអធិប្បាយថា៖ *ដូច*

*ជាអ៊ីស្រាអែលផងដែរ យើងមិនអាចមានសេរីភាពថ្វាយបង្គំព្រះជាម្ចាស់តាមចិត្តរបស់យើងចង់នោះទេ ប៉ុន្តែ*

*យើងត្រូវតែថ្វាយបង្គំតាមរបៀបដែលគាប់ព្រះហឫទ័យព្រះ គឺតាមព្រះបន្ទូលទ្រង់  ដែលជាការថ្វាយបង្គំដោយវិញ្ញាណ និងសេចក្តីពិត ដោយយើងទុកចិត្ត និងដើរតាមព្រះយេស៊ូវ។*

ការអនុវត្តចេញពីអត្ថបទសារនេះគឺថា គ្រីស្ទបរិស័ទត្រូវយកចិត្តទុកដាក់ក្នុងការស្តាប់ព្រះគម្ពីរ និងយកចិត្តទុកដាក់ចំពោះពួកជំនុំ ប្រយោជន៍អោយពួកគេចំរើនឡើងនៅក្នុងការយល់ដឹងព្រះបន្ទូល និងការថ្វាយបង្គំដោយវិញ្ញាណ និងសេចក្តីពិត ដែលជាអ្វីដែលព្រះជាម្ចាស់គាប់ព្រះហឫទ័យ។